ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

••• •••

បណ្តឹងរដ្ឋប្បវេណី

លេខ: ១២៩

ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១១

សាលក្រមរដ្ឋប្បវេណី

លេខ: ១៩ " ១ "

ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១១

# គាទនាមប្រជារាស្ត្រខ្មែរ

## សាលាដំបូងខេត្តបាត់ដំបង

បានបញ្ចប់នីតិវិធីនៃការទាញហេតុផលដោយផ្ទាល់មាត់នៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១១ ប្រកាសសាលក្រមនៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១១ ។

រវាងដើមចោទឈ្មោះ [redacted] សារ៉ុត ភេទស្រី អាយុ៦៣ឆ្នាំ ជាតិខ្មែរ ទីលំនៅសព្វថ្ងៃភូមិហៃសាន ឃុំជ្រៃ ស្រុកថ្មគោល ខេត្តបាត់ដំបង ឪពុកឈ្មោះ [redacted] សារិន (ស) ម្តាយឈ្មោះ [redacted] នឿម (រ) ប្តីឈ្មោះ [redacted] ជឿម ។

ដោយមានលោក[redacted] ជាមេធាវីតំណាងដោយអាណត្តិ ។

និងចុងចម្លើយឈ្មោះ [redacted] យុន ភេទស្រី អាយុ៧៦ឆ្នាំ ជាតិខ្មែរ មុខរបរជាវ ទីលំនៅសព្វថ្ងៃ ភូមិហៃសាន ឃុំជ្រៃ ស្រុកថ្មគោល ខេត្តបាត់ដំបង ឪពុកឈ្មោះ ទូច (ស) ម្តាយឈ្មោះ វ៉ាំង (ស) ។

ដោយមានលោក [redacted] ជាមេធាវីតំណាងដោយអាណត្តិ ។

<u>ខ្លឹមសារនៃសាលក្រមដែលដើមចោទទាមទារឱ្យតុលាការចេញ:</u>

១/ សុំគ្រប់គ្រងលើដីទំនាស់ទំហំ ២៩៩ម៉ែត្រក្រឡា ជាកម្មសិទ្ធិ មានព្រំប្រទល់ខាងជើងទល់ឈ្មោះ [redacted] អន ខាងត្បូងទល់ឈ្មោះ[redacted] សោភា ផ្លូវជាតិលេខ៥ ខាងកើតតល់ឈ្មោះ [redacted] សារ៉ុត ខាងលិចទល់ឈ្មោះ [redacted] សោភា ស្ថិតនៅភូមិហៃសាន ឃុំជ្រៃ ស្រុកថ្មគោល ខេត្តបាត់ដំបង ។

២/ សុំអោយឈ្មោះ [redacted] យុន រុះរើផ្ទះចេញពីដីទំនាស់ ។

៣/ សុំអោយចុងចម្លើយទទួលបន្ទុកបង់ប្រាក់ប្រដាប់ក្តី ។

<u>ខ្លឹមសារនៃសាលក្រមដែលចុងចម្លើយ និង ជាដើមបណ្តឹងតបទាមទារឱ្យតុលាការចេញ:</u>

១/ សុំលប់ចោលការទាមទាររបស់ដើមចោទ ក្នុងពាក្យបណ្តឹង ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១១ ទាំងមូល ។

២/ សុំអោយតុលាការរក្សានូវសេចក្តីសម្រេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិលេខ: ០១៤ គសជ/ សសវ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១១ ទុកជាបានការតាមច្បាប់ទាំងមូល ។

៣/ សុំគ្រប់គ្រងដីជាកម្មសិទ្ធិទំហំ ១៥០ម៉ែត្រក្រឡា ស្ថិតនៅភូមិហៃសាន ឃុំជ្រៃ ស្រុកថ្មគោល ខេត្តបាត់ដំបង មានព្រំប្រទល់ ខាងជើងទល់នឹងដីឈ្មោះ [redacted] អន ខាងត្បូងទល់ផ្លូវជាតិលេខ៥ ខាងកើតទល់នឹងដីឈ្មោះ [redacted] ជឿម និងប្រពន្ធឈ្មោះ [redacted] សារ៉ុត (ដើមចោទ) និងខាងលិចទល់ព្រំដីឈ្មោះ [redacted] មឿន ។

៤/ សុំទាមទារជម្ងឺចិត្តដែលធ្វើអោយខាតបង់ពេលវេលាដើរក្តីចំនួន ៥០០០ដុល្លារអាមេរិក ពីភាគីដើមចោទឈ្មោះ [redacted] សារ៉ុត ។

៥/ ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ ។

១៣៦
136

Scanned with CamScanner

## អង្គហេតុនិងចំណុចវិវាទ

### អង្គហេតុ

តាមពាក្យបណ្តឹងចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១១ របស់ដើមចោទឈ្មោះ [redacted] សារ៉ុត បានប្តឹងទាមទារសុំអោយតុលាការចេញសាលក្រមសម្រេច សុំគ្រប់គ្រងលើដីទំនាស់ទំហំ ២៩៩ម៉ែត្រក្រឡា ជាកម្មសិទ្ធិ មានព្រំប្រទល់ខាងជើងទល់ឈ្មោះ [redacted] អន ខាងត្បូងទល់ឈ្មោះ [redacted] សោភា ផ្លូវជាតិលេខ៥ ខាងកើតតល់ឈ្មោះ [redacted] សារ៉ុត ខាងលិចទល់ឈ្មោះ [redacted] សោភា ស្ថិតនៅភូមិហៃសាន ឃុំជ្រៃ ស្រុកថ្មគោល ខេត្តបាត់ដំបង . សុំអោយឈ្មោះ [redacted] យុន រុះរើផ្ទះចេញពីដីទំនាស់ . សុំអោយចុងចម្លើយទទួលបន្ទុកបង់ប្រាក់ប្រដាប់ក្តី ដោយមូលហេតុថា: នៅក្នុងឆ្នាំ ១៩៨៦ ខ្លួនបានទិញដីពីឈ្មោះ [redacted] សារឿន ដែលមានទំហំ ២៩៩ម៉ែត្រក្រឡា ក្នុងតម្លៃ ១០០០០រៀល លុះដល់ឆ្នាំ១៩៨៧ ឈ្មោះ [redacted] យុន បានសុំខ្លួនស្នាក់នៅបណ្តោះអាសន្នទំរាំដល់ថ្ងៃស្លាប់ ដោយគាត់មិនហ៊ានរស់នៅលើដីកម្មសិទ្ធិរបស់គាត់ដែលនៅពីក្រោយដីរបស់ខ្លួន ដោយបារម្ភណ៍ខ្លាចក្រែងមានការឈឺថ្កាត់យប់ព្រលប់ព្រោះគ្មានកូនចៅមើលថែទេ ។ លុះដល់ឆ្នាំ១៩៨៩ ខ្លួនបានធ្វើពាក្យកាន់កាប់ដីទំនាស់ព្រមទាំងដីកម្មសិទ្ធិរបស់ខ្លួនសរុបទាំងអស់ ៨០០ម៉ែត្រក្រឡា ។ ពេលនោះខ្លួនមិនបានចាប់អារម្មណ៍ថាឈ្មោះ [redacted] យុន បានធ្វើពាក្យសុំប្រកាសកាន់កាប់ដីទំនាស់នេះឬអត់ទេ ខ្លួនក៏ចេះតែអោយគាត់រស់នៅបន្តតាមការសុំស្នាក់នៅបណ្តោះអាសន្នរបស់គាត់ ។ ក្រោយមកខ្លួនបានអោយឈ្មោះ [redacted] យុន ចេញពីដីទំនាស់ ស្រាប់តែឈ្មោះនេះមិនព្រមចាកចេញទើបខ្លួនប្តឹងមកតុលាការតែម្តង ។

តាមពាក្យបណ្តឹងតបចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១១ របស់ចុងចម្លើយឈ្មោះ [redacted] យុន ប្តឹងសុំអោយតុលាការចេញសាលក្រមសម្រេច សុំលប់ចោលការទាមទាររបស់ដើមចោទក្នុងពាក្យបណ្តឹងចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១១ ទាំងមូល . សុំអោយតុលាការរក្សាទុកសេចក្តីសម្រេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិលេខ: ០១៤ គសជ/សសរ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១១ ទុកជាបានការតាមច្បាប់ទាំងមូល . សុំគ្រប់គ្រងដីជាកម្មសិទ្ធិទំហំ ១៥០ម៉ែត្រក្រឡា ស្ថិតនៅភូមិហៃសាន ឃុំជ្រៃ ស្រុកថ្មគោល ខេត្តបាត់ដំបង ដែលមានព្រំប្រទល់ ខាងជើងទល់នឹងដីឈ្មោះ [redacted] អន ខាងត្បូងទល់ផ្លូវជាតិលេខ៥ ខាងកើតទល់នឹងដីឈ្មោះ [redacted] ជឿម និងប្រពន្ធឈ្មោះ [redacted] សារ៉ុត (ដើមចោទ) និងខាងលិចទល់ព្រំដីឈ្មោះ [redacted] មឿន . សុំទាមទារជម្ងឺចិត្តដែលធ្វើអោយខាតបង់ពេលវេលាដើរក្តីចំនួន ៥០០០ដុល្លាអាមេរិក ពីភាគីដើមចោទឈ្មោះ [redacted] សារ៉ុត និងប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ ដោយមូលហេតុថា: ការលើកឡើងក្នុងពាក្យបណ្តឹងរបស់ដើមចោទចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១១ ពុំពិតទេ ហើយការរស់នៅរបស់ខ្លួននៅភូមិហៃសាន ឃុំជ្រៃ ស្រុកថ្មគោល ខេត្តបាត់ដំបង គឺចាប់តាំងពីឆ្នាំ១៩៧៩មក ចំណែកភាគីដើមចោទបានរស់នៅលើដីជាប់ព្រំបែកខាងកើតព្រំដីរបស់ខ្លួននៅឆ្នាំ១៩៨៦ ការចោទប្រកាន់ថាខ្លួនសុំ ដីដើមចោទរស់នៅបណ្តោះអាសន្ននោះពុំពិតទេ គឺដើមចោទជាអ្នករំលោភបំពានយកដីខ្លួន ដែលខ្លួនបានរស់នៅកាន់កាប់តាំងពីឆ្នាំ១៩៧៩ រហូតដល់បច្ចុប្បន្ននេះ ឯដើមចោទបានមករស់នៅក្រោយខ្លួនចំនួន៨ឆ្នាំ គិតពីឆ្នាំ១៩៧៩ មកទល់ឆ្នាំ១៩៨៦ ។

### ការអះអាងរបស់គូភាគី

- លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិ របស់ដើមចោទឈ្មោះ [redacted] សារ៉ុត បានធ្វើសេចក្តីថ្លែងការណ៍ថា: កូនក្តីរបស់ខ្លួនបានប្តឹងសុំអោយតុលាការចេញសាលក្រមសម្រេចអោយកូនក្តីរបស់ខ្លួនគ្រប់គ្រងជាបណ្តោះអាសន្នលើដីចំណីផ្លូវដែលមានទំហំ ១៩៨ម៉ែត្រក្រឡា និងសុំសិទ្ធិគ្រប់គ្រងលើកម្មសិទ្ធិដីទំហំ ១០១ម៉ែត្រ

ក្រឡា និងសុំអោយចុងចម្លើយរុះរើផ្ទះចេញពីដីកម្មសិទ្ធិដែលមានទំហំ ១០១ម៉ែត្រក្រឡា ដែលមានទីតាំងនិងព្រំប្រទល់ដូចកម្មវត្ថុខាងលើ និងសុំច្រានចោលសេចក្តីសម្រេចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិលេខៈ០១៤ គសជ/សសរ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១១ ទាំងស្រុង ដោយមូលហេតុថាៈ នៅឆ្នាំ១៩៨៦ កូនក្តីរបស់ខ្លួនបានទិញដីដែលមានទំហំ ២៩៩ម៉ែត្រក្រឡា ពីឈ្មោះ [redacted] សារឿន ក្នុងតម្លៃ ១០០០០រៀល ។ ក្រោយពីទិញដីនោះមក កូនក្តីខ្លួនបានប្រកាសកាន់កាប់រួមគ្នាជាមួយដីកម្មសិទ្ធិរបស់គាត់ក្នុងទំហំសរុប ៨០០ម៉ែត្រក្រឡា ក្នុងការទិញដីទំហំ ២៩៩ម៉ែត្រក្រឡានេះ គឺមានទំហំតែ ១០១ ម៉ែត្រក្រឡា ប៉ុណ្ណោះដែលមិនប៉ះពាល់ដីចំណីផ្លូវសាធារណៈ ឯចំណែក ១៩៨ម៉ែត្រក្រឡា គឺជាដីចំណីផ្លូវសាធារណៈ ដែលមាននៅក្នុងគំនូសប្លង់ទីតាំងចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០០៤ ។ នៅក្នុងឆ្នាំ១៩៨៧ កូនក្តីរបស់ខ្លួនបានធ្វើរោងជួសជុលម៉ូតូនៅលើដីផ្នែកខាងមុខ ក្រោយមកឈ្មោះ [redacted] យុន បានប្តឹងសុំអោយកូនក្តីរបស់ខ្លួនរុះរើរោងជួសជុលម៉ូតូនេះចេញពីដីផ្នែកខាងមុខក្នុងឆ្នាំ២០០៤ ក្រោយមក បានប្តឹងបន្តទៅគណៈកម្មការសុរិយោដីរហូតមកដល់ឆ្នាំ២០១១ នេះ ទើបគណៈកម្មការសុរិយោដីបានអោយកូនក្តី របស់ខ្លួនរុះរើរោងជួសជុលម៉ូតូចេញពីដីចំណីផ្លូវនោះ ដែលក្នុងនោះចុងចម្លើយគ្រាន់តែប្តឹងសុំបើកច្រកចេញចូលអោយមានភាពទូលាយប៉ុណ្ណោះ បែរជាគណៈកម្មការសុរិយោដីថ្នាក់ជាតិសម្រេចអោយមានភាពស្មុគស្មាញទៅវិញ ។

ខ្លួនសុំបញ្ជាក់ថា បើចុងចម្លើយអះអាងថាដីទំហំ ១៩៨ម៉ែត្រក្រឡា និង ១០១ម៉ែត្រក្រឡា ជាដីរបស់ខ្លួន ម្តេចក៏មិនប្តឹងពីមុនមក ហេតុដូចម្តេចបានទើបតែប្តឹងនៅពេលនេះ ។ នៅចំពោះមុខនេះ កូនក្តីខ្លួនសុំសិទ្ធិរស់នៅគ្រប់គ្រងជាបណ្តោះអាសន្ននៅលើដីដែលបានសង់រោងពីឆ្នាំ១៩៨៧ មក ដោយសុខចិត្តទុកផ្លូវអោយចុងចម្លើយសម្រាប់ចេញចូលទំហំ២ម៉ែត្រ ហើយដីនោះកូនក្តីខ្លួននឹងប្រគល់ជូនរដ្ឋវិញនៅពេលរដ្ឋត្រូវការចាំបាច់ដើម្បីប្រយោជន៍រដ្ឋ ។ ឯចំណែកដីទំហំ ១០១ម៉ែត្រក្រឡា កូនក្តីខ្លួនសុំគ្រប់គ្រងជាកម្មសិទ្ធិ និងសុំអោយចុងចម្លើយរុះរើផ្ទះចេញពីដីទំនាស់នេះ ព្រោះថាកូនក្តីខ្លួនបានដាក់ពាក្យសុំកាន់កាប់ប្រើប្រាស់ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៨៩ និងបានទទួលបង្កាន់ដៃលេខៈ ២៤២១ ឃជ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៨៩ រួចហើយ ។

- ការអះអាងរបស់ដើមចោទឈ្មោះ [redacted] សារ៉ុត ថាៈ ខ្លួនឯកភាពទាំងស្រុងតាមសេចក្តីថ្លែងការណ៍របស់មេធាវីតំណាងដោយអាណត្តិរបស់ខ្លួន ដោយខ្លួនសុំអះអាងបន្ថែមថាខ្លួនសំណូមពរសុំកាន់កាប់ប្រើប្រាស់លើដីចំណីផ្លូវដែលមានរោងជួសជុលម៉ូតូនោះជាបណ្តោះអាសន្ន ព្រោះអីនៅតំបន់នោះប្រជាពលរដ្ឋប្រើប្រាស់ផ្លូវសាធារណៈនោះស្ទើរតែគ្រប់គ្រួសារ តែមិនទាន់ឃើញមានការជូនដំណឹងណាមួយពីអាជ្ញាធរមានសមត្ថកិច្ចអោយរុះរើទេ ម្យ៉ាងទៀតរោងជួសជុលម៉ូតូ របស់ខ្លួននោះបានសង់តាំងពីឆ្នាំ១៩៨៧ មកម្ល៉េះ ។

មកដល់ពេលនេះខ្លួនសុខចិត្តទុកដីប្រវែង២ម៉ែត្រ នៅផ្នែកខាងលិចដីរបស់ខ្លួន ដើម្បីអោយចុងចម្លើយនិងប្រជាពលរដ្ឋនៅក្បែរខាងនោះអាចឆ្លងកាត់ទៅកាន់ផ្លូវជាតិបាន ខ្លួនសន្យាថានឹងរុះរើរោងជួសជុលម៉ូតូនោះចេញភ្លាមនៅពេលណាមានការជូនដំណឹងពីអាជ្ញាធរមានសមត្ថកិច្ចអោយរុះរើដើម្បីអភិវឌ្ឍន៍ ឬពង្រីកផ្លូវនៅទីនោះ ឬក៏ជាប្រយោជន៍សាធារណៈណាមួយដែលបានតម្រូវដោយមិនមានការតវ៉ាអ្វីទេ ។

- លោក [redacted] ជាមេធាវីតំណាងដោយអាណត្តិ របស់ចុងចម្លើយឈ្មោះ [redacted] យុន បានធ្វើសេចក្តីថ្លែងការណ៍ថាៈ កូនក្តីរបស់ខ្លួនបានប្តឹងសុំអោយតុលាការតម្កល់សេចក្តីសម្រេចលេខៈ ០១៤ គសជ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១១ របស់គណៈកម្មការសុរិយោដីថ្នាក់ជាតិទាំងស្រុង សុំគ្រប់គ្រងដីជាកម្មសិទ្ធិទំហំ ១៥០ម៉ែត្រក្រឡា មានព្រំប្រទល់ខាងជើងទល់នឹងដីឈ្មោះ [redacted] អន ខាងត្បូងទល់ផ្លូវជាតិលេខ៥ ខាងកើតទល់នឹងដីឈ្មោះ [redacted] ជឿម និងប្រពន្ធឈ្មោះ [redacted] សារ៉ុត និងខាងលិចទល់នឹងដីឈ្មោះ [redacted] មឿន ដែលមានទីតាំងស្ថិតនៅភូមិ

ហៅសាន ឃុំជ្រៃ ស្រុកថ្មគោល ខេត្តបាត់ដំបង សុំទាមទារជម្ងឺចិត្តខាតបង់ពេលវេលាចំនួន ៥០០០ដុល្លាអាមេរិក និងសុំច្រានចោលការទាមទាររបស់ដើមចោទទាំងស្រុងដោយមូលហេតុថា: វិវាទដីធ្លីនេះ កូនក្តីរបស់ខ្លួនបានប្តឹងដើមចោទតាំងពីឆ្នាំ២០០០ ដោយសារដើមចោទបានបំពារបំពានសិទ្ធិកាន់កាប់ដី ការប្តឹងនេះចូលទៅសមត្ថកិច្ចឃុំជ្រៃ តែដោះស្រាយមិនជោគជ័យដោយសារដើមចោទមិនអនុវត្ត ។ បន្ទាប់មកកូនក្តីខ្លួនបានដាក់ពាក្យចូលទៅគណៈកម្ម-ការសុរិយោដីស្រុកថ្មគោលនៅថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០០៣ ដល់ឆ្នាំ២០០៤ សុរិយោដីស្រុកថ្មគោលបានចុះធ្វើការស៊ើបអង្កេតដល់ទីតាំងដីទំនាស់ច្រើនលើកច្រើនសា តែមិនបានជោគជ័យដដែល ទើបមកដល់ថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១១ គណៈកម្មការសុរិយោដីថ្នាក់ជាតិបានចេញសេចក្តីសម្រេចលេខ: ០១៤ គសជ/សសរ ចុះថ្ងៃ ទី០៨ ខែកុម្ភៈ ឆ្នាំ២០១១ អោយភាគី [redacted] សារ៉ុត រុះរើរោងជួសជុលម៉ូតូចេញពីដីទំនាស់នេះ ។ មុននឹងសម្រេចសេចក្តីគឺបានចុះធ្វើការស៊ើបអង្កេតដល់ទីតាំងដីទំនាស់ សាកសួរសាក្សី និងរដ្ឋអំណាចមូលដ្ឋានបានល្អិតល្អន់ទៀត ។

- ចំពោះដីទំហំ ១៥០ម៉ែត្រក្រឡា ដែលមានទីតាំង និងព្រំប្រទល់ដូចក្នុងកម្មវត្ថុបណ្តឹងនោះ គឺកូនក្តីខ្លួនបានកាន់កាប់គ្រប់គ្រងតាំងពីឆ្នាំ១៩៧៩មក និងបានដាក់ពាក្យសុំកាន់កាប់ប្រើប្រាស់ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៨៩ និងបានទទួលបង្កាន់ដៃលេខ: ២៤២១ ឃជ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៨៩ ។

ខ្លួនសុំលោកចៅក្រមពិនិត្យលើភស្តុតាងរបស់ដើមចោទ លើពាក្យស្នើសុំកាន់កាប់ដីធ្លីចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ១៩៨៩ និងការអះអាងរបស់គាត់ថាទិញដីឈ្មោះ [redacted] សារឿន នៅឆ្នាំ១៩៨៦ ពុំមានភាពត្រឹមត្រូវទេ ព្រោះអីលិខិតកាន់កាប់ប្រើប្រាស់ដីចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៨៩ របស់គាត់បានបញ្ជាក់ថា គាត់កាន់កាប់ចាប់ពីឆ្នាំ១៩៧៩ ផ្ទុយពីការអះអាងថាទិញពីឆ្នាំ១៩៨៦ ។ សំណូមពរ សុំអោយតុលាការច្រានចោលការប្តឹងការទាមទាររបស់ភាគីដើមចោទ ព្រោះការប្តឹងនេះជាលេសដើម្បីពន្យាពេលប៉ុណ្ណោះ និងសុំទទួលយកពាក្យបណ្តឹងតប និងសម្រេចតាមការស្នើសុំរបស់កូនក្តីខ្លួន ។

**សំអាងហេតុ**

- តាមសេចក្តីថ្លែងការណ៍របស់មេធាវីតំណាងដោយអាណត្តិរបស់ដើមចោទថា: ខ្លួនប្តឹងសុំគ្រប់គ្រងជាបណ្តោះអាសន្នលើដីចំណីផ្លូវទំហំ ១៩៨ម៉ែត្រក្រឡា និងសុំសិទ្ធិលើកម្មសិទ្ធិដីទំហំ ១០១ម៉ែត្រក្រឡា សុំចុងចម្លើយរុះរើផ្ទះចេញពីដីទំហំ ១០១ម៉ែត្រក្រឡានោះ ព្រមទាំងសុំច្រានចោលសេចក្តីសម្រេចលេខ: ០១៤ គសជ/សសរ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១១ របស់គណៈកម្មការសុរិយោដីថ្នាក់ជាតិទាំងស្រុង ។

- តាមសេចក្តីថ្លែងការណ៍របស់មេធាវីតំណាងដោយអាណត្តិរបស់ចុងចម្លើយថា: សុំតុលាការតម្កល់សេច-ក្តីសម្រេចលេខ: ០១៤ គសជ/សសរ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១១ របស់គណៈកម្មការសុរិយោដីថ្នាក់ជាតិទាំងស្រុង សុំគ្រប់គ្រងដីកម្មសិទ្ធិទំហំ ១៥០ម៉ែត្រក្រឡា សុំទាមទារជម្ងឺចិត្តពីដើមចោទចំនួន ៥០០០ដុល្លាអាមេរិក និងសុំច្រានចោលការទាមទាររបស់ដើមចោទទាំងស្រុង ។

- តាមសេចក្តីថ្លែងការណ៍របស់មេធាវីទាំងពីរខាងលើឃើញថា កម្មវត្ថុវិវាទនៃរឿងនេះគឺសេចក្តីសម្រេចលេខ: ០១៤ គសជ/សសរ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១១ របស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ និងដីទំហំ ១០១ម៉ែត្រក្រឡា (ការអះអាងរបស់ដើមចោទ) ឬ ១៥០ម៉ែត្រក្រឡា (ការអះអាងរបស់ចុងចម្លើយ) គឺជាដីតែមួយកន្លែង ។

- តាមភស្តុតាងគំនូសប្លង់ទីតាំងដីទំនាស់ចុះថ្ងៃទី១១ ខែមករា ឆ្នាំ២០០៤ បញ្ជាក់ថាដីទំហំ ១៥៨ម៉ែត្រ-ក្រឡា ខាងលើនេះមានចម្ងាយ ៣០ម៉ែត្រពីអ័ក្សផ្លូវជាតិលេខ៥ ដែលតាមសេចក្តីប្រកាសលេខ ០៦... ចុះថ្ងៃ

ទី២៧ ខែកញ្ញា ឆ្នាំ១៩៩៩ របស់រាជរដ្ឋាភិបាលកំណត់ចំណីផ្លូវជាតិលេខ៥ មានចម្ងាយ៣០ម៉ែត្រពីអ័ក្សផ្លូវ ឃើញថាដីទំនាស់ខាងលើ ពិតជាដីចំណីផ្លូវ ដែលជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋប្រាកដមែន ដូចនេះការដែលគណៈកម្មការសុរិយោដីថ្នាក់ជាតិ រក្សាដីនេះទុកជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ មានលក្ខណៈត្រឹមត្រូវតាមផ្លូវច្បាប់ ។

- ដើមចោទឈ្មោះ [redacted] សារ៉ុត អះអាងថាៈ នៅតំបន់នោះប្រជាពលរដ្ឋប្រើប្រាស់ផ្លូវសាធារណៈស្ទើរតែគ្រប់គ្រួសារ តែមិនទាន់ឃើញមានការជូនដំណឹងណាមួយពីអាជ្ញាធរមានសមត្ថកិច្ចអោយរុះរើទេ ម្យ៉ាងទៀតរោងជួសជុលម៉ូតូរបស់ខ្លួននោះបានសង់តាំងពីឆ្នាំ១៩៨៧មកម្ល៉េះ ការលើកឡើងនូវអង្គហេតុនេះត្រឹមត្រូវតាមភាពជាក់ស្តែង និងមិនត្រូវបានជំទាស់ពីមេធាវីតំណាងដោយអាណត្តិរបស់ចុងចម្លើយទេ ដូចនេះអង្គហេតុនេះជាអង្គហេតុពិត

- ការដែលដើមចោទកាន់កាប់ប្រើប្រាស់លើដីចំណីផ្លូវតាំងពីឆ្នាំ១៩៨៧ ហើយគ្មានការជូនដំណឹងអោយរុះរើពីអាជ្ញាធរមានសមត្ថកិច្ច នេះបង្ហាញថា រដ្ឋមិនទាន់មានតម្រូវការចាំបាច់ដើម្បីអភិវឌ្ឍន៍ ឬពង្រីកផ្លូវនៅតំបន់នោះនៅឡើយ ឯរោងជួសជុលម៉ូតូនោះក៏ពុំមានប៉ះពាល់ដល់ប្រយោជន៍សាធារណៈណាមួយដែរ ដូចនេះការអនុញ្ញាតអោយដើមចោទកាន់កាប់ប្រើប្រាស់រោងជួសជុលម៉ូតូនោះជាបណ្តោះអាសន្នបន្តទៅទៀត រហូតមានតម្រូវការរបស់រដ្ឋនោះពុំមានអ្វីប៉ះពាល់ដល់ប្រយោជន៍សាធារណៈនៅតំបន់នោះទេ ។

- ដើមចោទឈ្មោះ. [redacted] សារ៉ុត បានសន្យានៅមុខសវនាការជាសាធារណៈថា ខ្លួននឹងរុះរើរោងជួសជុលម៉ូតូនោះចេញភ្លាមនៅពេលណាមានការជូនដំណឹងពីអាជ្ញាធរមានសមត្ថកិច្ចអោយរុះរើ ដើម្បីអភិវឌ្ឍន៍ ឬពង្រីកផ្លូវនៅទីនោះឬប្រយោជន៍សាធារណៈណាមួយតម្រូវ ការសន្យានេះមានលក្ខណៈសមស្របតាមច្បាប់និងល្មមទុកចិត្តបាន

- ដើមចោទឈ្មោះ [redacted] សារ៉ុត សុខចិត្តទុកដីប្រវែង ២ម៉ែត្រនៅផ្នែកខាងលិចដី ដើម្បីអោយចុងចម្លើយឈ្មោះ [redacted] យុន និងប្រជាពលរដ្ឋនៅក្បែរនោះឆ្លងទៅកាន់ផ្លូវជាតិ នេះមានលក្ខណៈសមស្របល្មមនឹងតម្រូវការរបស់ចុងចម្លើយ និងប្រជាពលរដ្ឋនៅក្បែរនោះ ។

- ដើមចោទប្តឹងសុំសិទ្ធិលើកម្មសិទ្ធិដីទំហំ ១០១ម៉ែត្រក្រឡា ដោយសំអាងថា ខ្លួនមានភស្តុតាងពាក្យសុំកាន់កាប់និងប្រើប្រាស់ដីផ្ទះចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ១៩៨៩ និងបង្កាន់ដៃទទួលពាក្យលេខៈ ១២៩៣៨ ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ១៩៩២ ជាភស្តុតាង ឯចុងចម្លើយប្តឹងតបសុំសិទ្ធិលើកម្មសិទ្ធិដីទំហំ ១៥០ម៉ែត្រក្រឡា ដោយសំអាងថាខ្លួនមានភស្តុតាង ពាក្យសុំកាន់កាប់ដីផ្ទះចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ១៩៨៩ និងបង្កាន់ដៃទទួលពាក្យលេខៈ ១៥១២៧ ចុះថ្ងៃទី២៧ ខែឧសភា ឆ្នាំ១៩៩២ ជាភស្តុតាង ។

- ដីទំហំ ១០១ម៉ែត្រក្រឡា (តាមការអះអាងរបស់ដើមចោទ) និងដីទំហំ ១៥០ម៉ែត្រក្រឡា (តាមការអះអាងរបស់ចុងចម្លើយ) គឺជាដីតែមួយកន្លែងត្រួតគ្នា គ្រាន់តែមានការអះអាងទំហំខុសគ្នាប៉ុណ្ណោះ ដីនេះមិនស្ថិតនៅលើដីចំណីផ្លូវទេ គឺជាដីកម្មសិទ្ធិឯកជនដែលត្រូវសម្រេចអំពីអត្ថិភាពនៃសិទ្ធិលើកម្មសិទ្ធិនេះ ប៉ុន្តែដោយដីខាងលើមិនទាន់មានប័ណ្ណរឹងនៅឡើយ ដូចនេះវិវាទនេះគឺជាសមត្ថកិច្ចរបស់គណៈកម្មការសុរិយោដីដែលការប្តឹងទាមទារនេះគណៈកម្មការសុរិយោដីមិនទាន់បានសម្រេចនៅឡើយ គប្បីតុលាការបង្វិលចំណែកបណ្តឹងនេះទៅគណៈកម្មការសុរិយោដីចាត់ការតាមសមត្ថកិច្ច ។

- បណ្តឹងរបស់ដើមចោទសុំអោយចុងចម្លើយរុះរើផ្ទះចេញពីដីទំហំ ១០១ម៉ែត្រក្រឡា គឺជាបណ្ដឹងចំណុះទៅនឹងបណ្តឹងសុំសិទ្ធិលើកម្មសិទ្ធិដីខាងលើ ។



Scanned with CamScanner

- បណ្ដឹងតបរបស់ចុងចម្លើយសុំទាមទារជម្ងឺចិត្តចំនួន ៥០០០ដុល្លាអាមេរិក ចុងចម្លើយពុំបានបញ្ជាក់អំពីភស្តុតាងស្ដីពីកំហុស ការខូចខាតនិងទំនាក់ទំនងហេតុផលរវាងកំហុសនិងការខូចខាតឡើយ ម្យ៉ាងទៀតហេតុដែលនាំអោយប្ដឹងផ្ដល់គ្នានេះមិនមែនជាកំហុសរបស់ដើមចោទទេ ដូចនេះមិនមានមូលដ្ឋានណាមួយក្នុងការសម្រេចឡើយ ។

- អត្ថិភាពនៃសិទ្ធិលើការទាមទាររបស់ដើមចោទ និងចុងចម្លើយខាងលើមានភាពប្រហាក់ប្រហែលគ្នា ដូចនេះបន្ទុកលើប្រាក់ប្រដាប់ក្ដីក្នុងរឿងនេះគប្បីអោយគូភាគីទទួលខុសត្រូវស្មើគ្នា ។

## <u>សេចក្ដីសម្រេចបញ្ចប់</u>

១/ តម្កល់សេចក្ដីសម្រេចលេខៈ ០១៤ គសជ/សសរ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១១ របស់គណៈកម្មការសុរិយោដីថ្នាក់ជាតិទុកជាបានការ លើកលែងតែចំណុចទី១ ដែលសម្រេចអោយភាគីចុងបណ្ដឹងរុះរើរោងជួសជុលម៉ូតូចេញពីដីទំនាស់នោះ ត្រូវធ្វើការកែប្រែដូចតទៅៈ

ក- រក្សាសិទ្ធិក្នុងការប្រើប្រាស់រោងជួសជុលម៉ូតូនោះដល់ដើមចោទជាបណ្ដោះអាសន្ន រហូតមានការជូនដំណឹងអោយរុះរើពីអាជ្ញាធរមានសមត្ថកិច្ចក្នុងគោលដៅអភិវឌ្ឍន៍ ឬពង្រីកផ្លូវដើម្បីជាប្រយោជន៍សាធារណៈណាមួយនៅតំបន់នោះ ។

ខ- បង្គាប់អោយឈ្មោះ [redacted] សារ៉ុត ទុកផ្លូវចេញចូលប្រវែង ២ម៉ែត្រ នៅផ្នែកខាងលិចដីសម្រាប់អោយចុងចម្លើយឈ្មោះ [redacted] យុន និងប្រជាពលរដ្ឋនៅក្បែរនោះឆ្លងកាត់ទៅផ្លូវជាតិលេខ៥ ។

២/ បង្វិលចំណែកបណ្ដឹងរបស់ដើមចោទសុំគ្រប់គ្រងដីទំហំ ១០១ម៉ែត្រក្រឡា និងចំណែកបណ្ដឹងតបរបស់ចុងចម្លើយសុំគ្រប់គ្រងដីទំហំ១៥០ម៉ែត្រក្រឡាទៅគណៈកម្មការសុរិយោដីថ្នាក់ជាតិដើម្បីដោះស្រាយតាមសមត្ថកិច្ច

៣/ ច្រានចោលការទាមទាររបស់ចុងចម្លើយក្នុងបណ្ដឹងតបត្រង់ចំណុចទាមទារជម្ងឺចិត្តចំនួន ៥០០០ដុល្លាអាមេរិក( ប្រាំពាន់) ទាំងស្រុង ។

៤/ ប្រាក់ប្រដាប់ក្ដីនៅក្នុងរឿងនេះជាបន្ទុករបស់គូភាគីចំនួនពាក់កណ្ដាលម្នាក់ ។

**ចៅក្រមជំនុំជម្រះ**

ហត្ថលេខា និង ត្រា

[redacted]

---

**បានឃើញ**

ចៅក្រម

[redacted]

បានចម្លងត្រឹមត្រូវតាមមូលសាលក្រម

បាត់ដំបង.ថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១១

ក្រឡាបញ្ជី

[redacted]

បានទទួល

ថ្ងៃទី 28 ខែ ធ្នូ ឆ្នាំ 2011

ស្នាមមេដៃស្ដាំ

[redacted]

១៤១

141